# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសំរេចបន្តអាណត្តិអាជ្ញាប័ណ្ណរួមលេខ ០២៩ ឯអ
## សំរាប់លោក សុខ ធី
# អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណលេខ០២៩ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានចេញឱ្យលោក សុខ ធី នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៣

-យោងពាក្យស្នើសុំបន្តអាណត្តិអាជ្ញាប័ណ្ណ របស់លោក សុខ ធី ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៤

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៤ ដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៥

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី៤៩ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៥

## សំរេច

**ប្រការ១**

អាជ្ញាធរអគ្គិសនីកម្ពុជា សំរេចបន្តអាណត្តិអាជ្ញាប័ណ្ណលេខ ០២៩ឯអ ចុះ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៣ ដែលបានផ្តល់ជូនលោក សុខ ធី សំរាប់ធ្វើ សេវាកម្មអគ្គិសនីនៅទីប្រជុំជនផ្សារវាលរេញ ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។

**ប្រការ២**

ដោយលោក សុខ ធី បានធ្វើការកែលំអមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់ខ្លួនបានមួយចំនួនធំហើយត្រូវធ្វើការកែលំអបន្តទៀតនៅឆ្នាំបន្តបន្ទាប់ ដើម្បីឱ្យសមស្របតាមស្តង់ដាបច្ចេកទេស អាជ្ញាធរអគ្គិសនីកម្ពុជា សំរេចបន្តអាណត្តិបន្ថែមទៀតឱ្យលោក ។ អាណត្តិនេះមានរយៈពេល ០៥ (ប្រាំ)ឆ្នាំ១គិតចាប់ពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៥ និងអាចស្នើសុំបន្តទៀតឬស្នើសុំកែសំរួលបាន លើកលែងតែត្រូវដកហូតដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។

**ប្រការ៣**

សេចក្តីសំរេចនេះ ត្រូវក្លាយជាផ្នែកមួយនៃអាជ្ញាប័ណ្ណលេខ ០២៩ ឯអ ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០២៩ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៦**

សេចក្តីសំរេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៧**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើរសេចក្តីសំរេចនេះ ទៅតំកល់ទុកបន្ថែមនៅតាមទីកន្លែង ដែលឯកសារអាជ្ញាប័ណ្ណលេខ ០២៩ឯអ ដែលបានតំកល់ទុកពីមុន ដើម្បីឲ្យឯកសារអាជ្ញាប័ណ្ណលេខ ០២៩ឯអ ដែលតំកល់ទុកមានការកែសំរួលជាថ្មី ស្របតាមសេចក្តីសំរេចនេះ ។

ភ្នំពេញ, ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៥

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

## ឧបសម្ព័ន្ធទី២

## មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ

### ក_មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ

**រោងម៉ាស៊ីន**

១- រោងម៉ាស៊ីនរបស់អ្នកកាន់អាជ្ញាប័ណ្ណ គឺរោងសាងសង់ដោយជញ្ជាំងថ្ម ដំបូលបេតុង ទំហំ ១២ x ៨ ម៉ែត្រ ស្ថិតក្នុងភូមិបឹងវែង សង្កាត់ វាលរេញ ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។

**លក្ខណៈទូទៅនៃម៉ាស៊ីន**

១- អ្នកកាន់អាជ្ញាប័ណ្ណ មានម៉ាស៊ីនភ្លើងចំនួន ០៥គ្រឿង ដែលមានអានុភាព តំឡើងសរុប 860 kVA គឺ:

- –ម៉ាស៊ីនទី១ : អានុភាពដើម 250 kVA
- –ម៉ាស៊ីនទី២ : អានុភាពដើម 250 kVA
- –ម៉ាស៊ីនទី៣ : អានុភាពដើម 230 kVA
- –ម៉ាស៊ីនទី៤ : អានុភាពដើម 80 kVA
- –ម៉ាស៊ីនទី៥ : អានុភាពដើម 50 kVA

២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងដ្យេសែល ។

៣- សំភារៈផ្សេងៗ

- –ពោងផ្ទុកប្រេងចំណុះ ៥០០ លីត្រ ចំនួន ១ ។
- –ពោងផ្ទុកប្រេងចំណុះ ៨០០០ លីត្រ ចំនួន ១ ។

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីសម្រេចកែសម្រួលអាជ្ញាប័ណ្ណលើកទី៣
## លើឯកសារអាជ្ញាប័ណ្ណ លេខ ០២៩ ឯអ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៣
## ជាមួយសេចក្តីសម្រេចកែសម្រួលលើកទី២ លេខ០២២ សរ.០៦ អអក
## ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០០៦ សម្រាប់លោក សុខ ធី

## អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណរួមរបស់លោក សុខ ធី លេខ ០២៩ ឯអ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៣

-លិខិតស្នើសុំពង្រីកតំបន់ចែកចាយអគ្គិសនីរបស់លោក សុខ ធី ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៦

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០០៦ ដល់ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០០៦

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី ៨៦ នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៦

## សម្រេច

### ប្រការ១

កែសម្រួលអាជ្ញាប័ណ្ណលេខ ០២៩ ឯអ ដែលបានផ្តល់ឱ្យលោក សុខ ធី ដោយបន្ថែមតំបន់នៅភូមិជើងគោ សង្កាត់ជើងគោ ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ លើតំបន់ដែលមានស្រាប់ដូចមានបង្ហាញក្នុងផែនទីភ្ជាប់ ក្នុងឧបសម្ព័ន្ធទី ១ ដើម្បីអនុញ្ញាតឱ្យធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ ។

### ប្រការ២

ឧបសម្ព័ន្ធទី១ នៃអាជ្ញាប័ណ្ណលេខ ០២៩ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។

### ប្រការ៣

សេចក្តីសម្រេចនេះ និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ត្រូវក្លាយជាផ្នែកមួយ នៃអាជ្ញាប័ណ្ណលេខ ០២៩ ឯអ ។

### ប្រការ៤

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃអាជ្ញាប័ណ្ណលេខ ០២៩ ឯអ និងខ្លឹមសារដែលបានកែសម្រួលរួចហើយត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតំកល់ទុកបន្ថែមនៅតាម ទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០២៩ ឯអ បានតំកល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណ លេខ ០២៩ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៦

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

**ឧបសម្ព័ន្ធទី១**

**តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី**

**ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា**

**លើកទី ៨៦ នាថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៦**

១- តំបន់អនុញ្ញាតឱ្យលោក សុខ ធី ធ្វើសេវាកម្មចែកចាយនិងផ្គត់ផ្គង់អគ្គិសនីនៅទីប្រជុំជនផ្សារវាលរេញ និងភូមិជើងគោ សង្កាត់ជើងគោ ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ (មានបង្ហាញក្នុងផែនទីភ្ជាប់) ។

២- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើ លោក សុខ ធី មានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀតពេលនោះ លោក សុខ ធី ត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្តីសំរេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួល ដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិការ ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។